# ប្រាសាទព្រះវិហារ

# នឹង

# ព្រឹត្តិការណ៍គួរចងចាំ

តុលាការយុត្តិធម៌អន្តរជាតិ តាមបណ្តឹងរបស់រដ្ឋាភិបាលហ៊ុន–សែនទើបបានបកស្រាយសាលក្រមឆ្នាំ១៩៦២ស្តីពីប្រាសាទព្រះវិហារម្តងទៀត កាលពីថ្ងៃទី១១វិច្ឆិកាឆ្នាំ២០១៣ថ្មីៗនេះ។ ការបកស្រាយ ( មិនមែនជាការកាត់ក្តីជាថ្មីទេ ) បានបញ្ជាក់យ៉ាងច្បាស់ថា ប្រាសាទព្រះវិហារនឹងទឹកដីជុំវិញដូចផែនទីដែលមានក្នុងឧបសម្ព័នទី១ត្រូវស្ថិតនៅក្រោមអធិបតេយ្យភាពស្រុកខ្មែរ។ អ្នកណាអបអរសាទរក៏មិនខុសអ្វី ឯអ្នកដែលមិនអបអរសាទរក៏មិនជាខុសអ្វីដែរ ដោយហេតុថាខ្មែរមិនបានចំណេញអ្វីបន្តិចណាឡើយ គឺបានត្រឹមរួចខ្លួនតែប៉ុននោះ។ តទៅនេះគឺជាព្រឹត្តការណ៍សំខាន់ខ្លះទាក់ទងរឿងព្រះវិហារដែលខ្មែរគួរចងចាំ។

– ថ្ងៃទី៩ខែវិច្ឆិកា ១៩៥៣ ខ្មែរប្រកាសឯករាជ្យ ( ឯករាជ្យពេញបរិបូរគឺនៅដើមឆ្នាំ១៩៥៤ ក្រោយពេលដែលបារាំងសេសប្រគល់ក្រសួងសេដ្ឋកិច្ច នឹងក្រសួងការបរទេសមកនរដ្ឋាភិបាលខ្មែរ )។ គួរកត់សំគាល់ថា ខ្មែរបានទទួលឯករាជភាពពេញបរិបូរមុនសន្និសិទ្ទក្រុងស្ហឺណែវស្តីពីឥណ្ឌូចិន។

– ឆ្នាំ១៩៥៤ បារាំងសេសដកទ័ពចុងក្រោយចេញពីស្រុកខ្មែរ។ ឆ្នាំដដែលនោះសៀមដាក់កងទ័ពចូលកាន់កាប់តំបន់ប្រាសាទព្រះវិហារ។

– ឆ្នាំ១៩៥៩ ប្រទេសខ្មែរតវ៉ា ប្តឹងទៅតុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ ប្រទេសហូឡង់។ មេធាវីទីមួយតំណាងភាគីខ្មែរគឺលោកឌីន អាឈីសុន Dean Acheson អតីតរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរីកាំង អមដោយលោកទ្រឿង កាងមេធាវីខ្មែរនឹងវរជនដទៃទៀត។

– ថ្ងៃទី១៥មិថុនា ឆ្នាំ១៩៦២ តុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេបានសំរេចថា ប្រាសាទព្រះវិ

ហារត្រូវនៅក្រោមអធិបតេយ្យភាពរបស់ខ្មែរ រួមទាំងទឹកដីដែលមានចែងក្នុងផែនទីឧបសម្ព័ន្ធទីមួយភ្ជាប់ជាមួយផង។ លើសពីនេះទៅទៀត តុលាការដដែលបានសំរេចទៀតថា សៀមត្រូវតែប្រគល់មកឱ្យខ្មែរវិញនូវបុរាណវត្ថុទាំងឡាយណាណាដែលសៀមបានលួចយកចេញពីប្រាសាទព្រះវិហារថែមទៀតផង។ សៀមមិនបានឈឺក្បាលហាលថ្ងៃអ្វីនឹងសាលក្រមរបស់តុលាការនេះដល់តិចតួចណាឡើយ។ កងទ័ពគេនៅតែកាន់កាប់ប្រាសាទព្រះវិហារនឹងទឹកដីជុំវិញដោយគ្មានកោតក្រែង។

– ឆ្នាំ១៩៦២ ( ថ្ងៃខែមិនដឹង ) តាមចាំកងទ័ពខ្មែរមួយកងអនុសេនាធំដឹកនាំដោយអនុសេនីយឯក ទៀប បែន ( ក្រោយមកជាមេបញ្ជាការកងទ័ពហ្វ៊ុន ស៊ិនប៉ិចនៅជាយដែនខ្មែរ–សៀម ) តោងវល្លិឡើងទៅវាយបណ្តេញទ័ពសៀមចេញបានដោយជោកជ័យកាន់កាប់ប្រាសាទនឹងដែនដីជុំវិញ។

– ឆ្នាំ១៩៦៣ សម្តេចសីហនុបានឡើងទៅកាន់កាប់តំបន់ប្រាសាទព្រះវិហារជាផ្លូវការ។ ក្នុងកាយវិការសម្របសម្រួលជាមួយសៀម ទ្រង់បានថ្លែងថា ជនជាតិថៃអាចចូលមកទស្សនាប្រាសាទព្រះវិហារបានដោយមិនចាំបាច់មានលិខិតឆ្លងដែនឬក៏ទិដ្ឋាការអ្វីឡើយ។ រីឯបុរាណវត្ថុដែលសៀមបានយកចេញពីប្រាសាទទៅ សៀមអាចរក្សាទុកចុះមិនបាច់ប្រគល់មកឱ្យខ្មែរវិញទេ។

គួរកត់សំគាល់ថា កងទ័ពខ្មែរសម័យសង្គមរាស្ត្រនិយម នឹងកងទ័ពខ្មែរសម័យសាធារណរដ្ឋគឺជាកងទ័ពតែមួយ។

– ថ្ងៃទី១៧មេសា ១៩៧៥ ខ្មែរក្រហមចូលក្រុងភ្នំពេញ។ កងទ័ពសាធារណរដ្ឋខ្មែរចាញ់ តែពួកគេកាន់កាប់តំបន់ព្រះវិហាររហូតដល់ថ្ងៃទី២២ឧសភា ១៩៧៥។

– ថ្ងៃទី៧មករា ១៩៧៩ យួនឈ្លានពានចូលកាន់កាប់ស្រុកខ្មែរ តែពួកខ្មែរក្រហមកាន់កាប់តំបន់ព្រះវិហាររហូតចុងឆ្នាំ១៩៩៨។

ខាងលើនេះបញ្ជាក់ឱ្យឃើញថាវិបត្តិព្រំដែនសៀម–ខ្មែរស្ងប់ស្ងាត់តាំងតែពីឆ្នាំ១៩៦៣រហូតមកទោះក្នុងរបបសង្គមរាស្ត្រនិយម របបសាធារណរដ្ឋខ្មែរ របបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមបងធំ

ក៏ដោយ។ បញ្ហាទើបតែកើតមាននៅសម័យខ្មែរក្រហមបងតូចដែលមានលោកហ៊ុន–សែនដឹកនាំស្រុក ហេតុអ្វី? នាទីនេះសូមមិនល្បងឆ្លើយរឿងនេះទេ តែបែរជាសូមអនុញ្ញាតិរំលឹកសោកនាដកម្មធំមួយខ្លាចខ្មែរភ្លេច។

ថ្ងៃទី១២មិថុនាឆ្នាំ១៩៧៩ ( ជិត៦ខែបន្ទាប់ពីថ្ងៃ«រំដោះ») រដ្ឋាភិបាលសៀមបានជូនដំណឹងអគ្គទូតនានៅក្រុងបាងកកថា គេនឹងបណ្ដេញជនភៀសខ្លួនខ្មែរមួយចំនួនធំចេញពីស្រុកគេ។ គេអនុញ្ញាតិឲ្យរដ្ឋាភិបាលអាមេរិកាំង បារាំងសេស នឹងអូស្ត្រាលី ជ្រើសយក១ ២០០នាក់ទៅជ្រកកោននៅឯប្រទេសទាំងឡាយនោះ។ ក្រៅអំពីនេះគេនឹងចាប់ដាក់ឡានយកទៅច្រានចោល។ ក្រោយមកទើបគេដឹងថា ជនភៀសខ្លួនខ្មែររាល់ម៉ឺននាក់បានត្រូវអាជ្ញាធរសៀមចាប់ញាត់ឡានដឹកយកទៅច្រានទម្លាក់ចោលនៅឯតំបន់ព្រះវិហារ ឲ្យដើរឆ្លងជំរាលភ្នំកាត់ចំការមីនចូលទៅស្រុកខ្មែរវិញ។ មន្ត្រីស្ថានទូតអាមេរិកាំងដែលលបតាមដានរឿងនេះ ប៉ាន់ស្មានថាយ៉ាងហោចណាស់ក៏មានជនភៀសខ្លួនខ្មែរចំនួន៤២ ០០០នាក់ដែរដែលត្រូវសៀមដឹកយកទៅទម្លាក់ចោលនៅតំបន់ព្រះវិហារនោះ។ ស្នងការជាន់ខ្ពស់អ.ស.ប.ផ្នែកជនភៀសខ្លួនក្រោយមកប៉ាន់ស្មានថា យ៉ាងហោចណាស់ក៏មានជនភៀសខ្លួនខ្មែរ៣ ០០០នាក់ដែរដែលបានបាត់បង់ជីវិត ហើយ៧ ០០០នាក់ទៀតបាត់ខ្លួន។ នៅទីបញ្ចប់ បានជារំលឹករឿងរ៉ាវដែលបានកើតឡើងខាងលើក៏ព្រោះតែរឿងនេះហាក់ដូចជាកំពុងពេញនិយម តែទោះជាយ៉ាងណាក៏ដោយគេមិនត្រូវដកភ្នែកចេញពីភូមិភាគខាងកើត នឹងនៅចំកណ្ដាលបេះដូងខ្មែរគឺក្រុងភ្នំពេញនោះឲ្យសោះ៕

អ៊ុម ហាក់

១៤វិច្ឆិកា ២០១៣